រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

020KH01A-01

នេហេមី :

របៀបធ្វើអោយបានសំរេចកិច្ចការធំៗ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

២0

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

អ្នកមានបំណងចង់បំរើព្រះអម្ចាស់ ដោយអស់ពីចិត្ត និងចង់ធ្វើកិច្ចការធំៗថ្វាយព្រះអង្គមែនទេ ! ខ្ញុំសង្ឃឹមដោយស្មោះថា ការសិក្សាដោយសង្ខេបពីលោកនេហេមីនេះនឹងជំរុញទឹកចិត្តអ្នកអោយអាចសំរេចបំណងទាំងនេះជាមិនខាន ។



កំណត់ចំណាំ

© Project WorldReach © SEAN

កំណត់ចំណាំ

កិច្ចការធំដែលលោកនេហេមីត្រូវប្រឈមមុខ

នៅឆ្នាំ ៥៨៦ មុនគ្រីស្តសករាជ ស្តេចនេប៊ូកានេសារបានកំទេចទីក្រុងយេរូសាឡឹម ហើយនាំយកពួកយូដា ដែលជាអ្នកជឿលើព្រះជាម្ចាស់ ចេញពីស្រុកយូដា ទៅធ្វើជាឈ្លើយសឹក ។ ប៉ុន្តែ ចក្រភពបាប៊ីឡូនរបស់ស្តេចនេប៊ូកានេសារ ក៏បានរលំរលាយទៅដោយសារពួកពែរ្សបានឈ្នះលើគេ ហើយពួកពែរ្សនេះបានអនុញ្ញាតឱ្យពួកយូដា ដែលជាកូនរបស់ព្រះជាម្ចាស់ វិលត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ។ ហេតុការណ៍ទាំងអស់នេះ កើតមានឡើងដូចដែលព្រះអម្ចាស់បានសន្យាមែន ។ ប៉ុន្តែ ទោះជាពួកគេបានវិលត្រឡប់មកនៅប្រទេសជាតិវិញ អស់រយៈពេលជិតមួយរយឆ្នាំហើយក៏ដោយ ក៏ទីក្រុងយេរូសាឡឹមនៅតែមានសភាពបាក់បែកខ្ទេចខ្ទីដដែល ។



លោកនេហេមីស្ថិត នៅប្រទេសពែរ្សនៅឡើយ ពីព្រោះលោកមានមុខតំណែងជា« មហាតលិករបស់ព្រះចៅអធិរាជ » ។ នៅពេលនោះ បងប្អូនរបស់លោកនេហេមីម្នាក់ឈ្មោះហាណានី បានធ្វើដំណើរពីស្រុកយូដា មកជួបនឹងលោកនេហេមី ។

ពួកអ្នកដែលបានរួចផុតពីការជាប់ជាឈ្លើយសឹក និងដែលបានវិលទៅស្រុកវិញ ហើយរស់នៅក្នុងអាណាខេត្តយូដានោះ បានរងទុក្ខវេទនា និងមានការអាម៉ាស់ជាខ្លាំង ។ រីឯកំពែងទីក្រុងយេរូសាឡឹមក៏បាក់បែក ហើយទ្វារទីក្រុងក៏ត្រូវភ្លើងឆេះអស់ដែរ ។



បើសិនជាព្រះជាម្ចាស់ត្រាស់ហៅអ្នក ហើយអ្នកធ្វើតាមគោលការណ៍ទាំងប្រាំពីរនេះ នោះអ្នកនឹងសំរេចកិច្ចការធំៗថ្វាយព្រះជាម្ចាស់ជាមិនខាន ។ សូមឱ្យព្រះជាម្ចាស់ប្រទានពរដល់អ្នក ពេលអ្នកធ្វើកិច្ចការបំរើព្រះជាម្ចាស់ ! ។



© Project WorldReach © SEAN

ការនិមិត្តឃើញរបស់លោកនេហេមី

ពេលលោកនេហេមីឮដំណឹងនេះ គាត់ក៏រញ្ជួយចិត្តជាខ្លាំង ។ គាត់ស្រក់ទឹកភ្នែកយ៉ាងជូរចត់ សោកសង្រេងយ៉ាងខ្លាំង ព្រមទាំងតមអាហារ ហើយនិងទូលអង្វរទៅព្រះជាម្ចាស់ ។



នេហេមីទូលព្រះអង្គដូចតទៅ : *«បពិត្រព្រះអម្ចាស់ ជាព្រះនៃស្ថានបរមសុខ ព្រះអង្គជាព្រះដ៏ឧត្តុង្គឧត្តម គួរស្ញែងខ្លាច ព្រះអង្គតែងតែរក្សាសម្ពន្ធមេត្រី ហើយសំដែងព្រះហឫទ័យមេត្តាករុណាចំពោះអស់អ្នកដែលស្រឡាញ់ព្រះអង្គ និងគោរពតាមបទបញ្ជារបស់ព្រះអង្គ ។ សូមផ្ទៀងព្រះកាណិស្តាប់ ព្រមទាំងទតមើលមក*

៧- លោកនេហេមីនៅតែខំព្យាយាម ទោះជាមានឧបសគ្គយ៉ាងណាក៏ដោយ ។

អ្នកដឹកនាំល្អមិនដែលបោះបង់កិច្ចការ នៅពេលមានឧបសគ្គនោះទេ ។ លោកនេហេមីត្រូវគេបៀតបៀនទាំងខាងក្នុងក្រុង និងទាំងខាងក្រៅ ក៏ប៉ុន្តែ លោកនៅតែអាចឃុំគ្រងបំណង កំឡាំង និងទឹកចិត្តស៊ូប្តូរធ្វើកិច្ចការរបស់លោកបានជានិច្ច ។ ព្រះយេស៊ូមានព្រះបន្ទូលថា÷

«អ្នកណាកាន់នង្គ័ល ហើយបែរជាងាកមើលក្រោយ អ្នកនោះគ្មានសារៈប្រយោជន៍អ្វីដល់ព្រះរាជ្យរបស់ព្រះជាម្ចាស់ឡើយ » ។

(លូកា ៩:៦២)

តើអ្នកមានបំណងចង់ខិតខំធ្វើកិច្ចការរបស់អ្នក អោយចប់សព្វគ្រប់ដែរឬទេ ?

ទូលបង្គំ សូមព្រះសណ្ដាប់ពាក្យទូលអង្វររបស់ទូលបង្គំ ជាអ្នកបំរើ
របស់ព្រះអង្គផង ។ ទូលបង្គំកំពុងតែទូលអង្វរនៅចំពោះព្រះភ័ក្ត្រ
របស់ព្រះអង្គ ទាំងថៃ ទាំងយប់ សូមព្រះអង្គប្រណីសន្ដោសជន
ជាតិអ៊ីស្រាអែលជាអ្នកបំរើរបស់ព្រះអង្គ ។ ទូលបង្គំសូមសារភាព
អំពើបាបក្នុងនាមជនជាតិអ៊ីស្រាអែល គឺយើងខ្ញុំបានប្រព្រឹត្តអំពើ
បាបទាស់នឹងព្រះហឫទ័យរបស់ព្រះអង្គ ។ ទូលបង្គំ និងក្រុម
គ្រួសាររបស់ទូលបង្គំ ក៏បានប្រព្រឹត្តអំពើបាបដែរ ។ យើងខ្ញុំពិត
ជាបានប្រព្រឹត្តខុសចំពោះព្រះអង្គ គឺយើងខ្ញុំពុំបានគោរពតាមបទ
បញ្ជាក្រឹត្យវិន័យ និងបញ្ញត្តិទាំងប៉ុន្មានដែលព្រះអង្គប្រទានមក
លោកម៉ូសេជាអ្នកបំរើរបស់ព្រះអង្គឡើយ ។

សូមនឹកចាំពីព្រះបន្ទូលដែលព្រះអង្គបានបង្គាប់មកលោកម៉ូសេ ជា
អ្នកបំរើរបស់ព្រះអង្គថា៖ "បើអ្នករាល់គ្នាមិនស្មោះត្រង់នឹងយើង
ទេនោះ យើងនឹងកំចាត់កំចាយអ្នករាល់គ្នាទៅនៅក្នុងចំណោមជាតិ
សាសន៍ទាំងឡាយ ។ ប៉ុន្តែ ប្រសិនបើអ្នករាល់គ្នាវិលមករកយើង
វិញ ហើយកាន់ និងប្រតិបត្តិតាមបទបញ្ជារបស់យើងនោះ ទោះបី
អ្នករាល់គ្នាត្រូវគេកៀរទៅនៅជើងមេឃក្ដី ក៏យើងប្រមូលផ្ដុំ និង
នាំអ្នករាល់គ្នាវិលត្រឡប់មកទីកន្លែង ដែលយើងបានជ្រើសរើស
សំរាប់សំដែងនាមយើងនេះវិញដែរ " ។

តើអ្នកផ្ទាល់ ច្រើនតែត្រួតត្រាលើគេខ្លាំង ឬ អ្នកជាស់តឿន
ជំរុញទឹកចិត្ត និងណែនាំប្រមូលពួកអ្នកដែលដើរតាមអ្នក ?

តើអ្នកមានគំរោងដូចម្ដេចខ្លះ ដើម្បីអោយអាចឈានដល់
គោលដៅរបស់អ្នក ?

© Project WorldReach © SEAN

តើអ្នកមានគំរោងដូចម្តេចខ្លះ ដើម្បីអោយអាចឈានដល់គោលដៅរបស់អ្នក ?

៦- លោកនេហេមីជំរុញទឹកចិត្ត និងណែនាំប្រមូលពួកអ្នកដែលដើរតាមគាត់ ។

អ្នកដឹកនាំពិតប្រាកដ ជាមនុស្សដែលធ្វើឱ្យសំរេចគោលដៅរបស់ខ្លួនតាមរយៈអ្នកដទៃ ។ អ្នកដឹកនាំនោះ សំរេចកិច្ចការដូចនេះបាន ដោយផ្តល់គំនិតដល់ពួកអ្នកទាំងនោះ ហើយប្រគល់អោយពួកគេធ្វើការងារផ្នែកណា ដែលពួកគេអាចធ្វើបាន ។

ដោយបណ្តាជនឃើញលក្ខណៈសម្បត្តិស្វាហាប់របស់លោកនេហេមី ទើបពួកគេដើរតាមលោក ដោយទឹកចិត្តពុះ-កញ្ជ្រោល ហើយម្នាក់ៗក៏បានសាងសង់កំពែងមួយផ្នែក ដែលស្ថិតនៅមុខទីលំនៅរបស់ពួកគេ ។

យើងខ្ញុំជាអ្នកបំរើរបស់ព្រះអង្គ ជាប្រជារាស្ត្រដែលព្រះអង្គបានរំដោះចេញពីស្រុកអេស៊ីប ដោយមហិទ្ធិឫទ្ធិ និងបារមីដ៏ខ្លាំងពូកែ ។ បពិត្រព្រះអម្ចាស់ សូមផ្ទៀងព្រះកាណិស្តាប់ពាក្យទូលអង្វររបស់ទូលបង្គំជាអ្នកបំរើរបស់ព្រះអង្គ ព្រមទាំងពាក្យទូលអង្វររបស់អ្នកបំរើឯទៀតៗ ដែលចង់គោរពកោតខ្លាចព្រះនាមរបស់ព្រះអង្គ ។ សូមប្រទានអោយទូលបង្គំទទួលជោគជ័យនៅថ្ងៃនេះ ហើយសូមអោយព្រះរាជាសន្តោសមេត្តាដល់ទូលបង្គំផង » ។

(នេហេមី ១:៥-១១)

ច្រើនខែក្រោយមក ព្រះអម្ចាស់បានប្រទានឱកាសពិសេសដល់លោកនេហេមី ។



ដោយសារព្រះរាជាសួរដូច្នេះ លោកនេហេមីភ័យរន្ធត់ជាខ្លាំង ហើយគាត់ត្រូវតែភ័យរន្ធត់ដូចនេះ ព្រោះនៅសម័យកាលនោះ ព្រះរាជាទាំងឡាយខ្លាចគេបំពុលណាស់ ហើយលោកនេហេមី មានតួនាទីការពារកុំឱ្យមានខ្មាំងសត្រូវដាក់ថ្នាំពុលក្នុងភេសជ្ជៈរបស់ព្រះចៅអធិរាជ ។





ហើយការនេះបង្ហាញយ៉ាងជាក់ស្តែងថា លោកនេហេមីមិនមែនទើបនឹងនឹកឃើញសេចក្តីទាំងនេះ នៅពេលទូលព្រះចៅអធិរាជនោះទេ គឺលោករៀបចំគំរោងយ៉ាងច្បាស់លាស់មុននឹងជួបជាមួយព្រះចៅអធិរាជ ។ ក្រោយមក ពេលទៅដល់ទីក្រុងយេរូសាឡឹម លោកនេហេមីមិនប្រញាប់ប្រញាល់ធ្វើគម្រោងភ្លាមៗទេ :

- លោកធ្វើសកម្មភាព ដោយចិត្តអត់ធ្មត់(រង់ចាំបីថ្ងៃ) ។
- លោកធ្វើសកម្មភាពដោយប្រុងប្រយ័ត្ន (ចេញដើរពេលយប់ ដោយសម្ងាត់) ។
- លោកធ្វើសកម្មភាពដោយហ្មត់ចត់ណាស់ (ពិនិត្យមើលគ្រប់យ៉ាងសព្វគ្រប់ ដោយខ្លួនឯង) ។

តើអ្នកបានវិភាគមើលស្ថានភាពរបស់អ្នក ដោយហ្មត់ចត់ឬទេ ?

តើអ្នកធ្វើដូចម្តេចខ្លះ ដើម្បីបែងចែកភារៈកិច្ចអោយអ្នកឯទៀតទទួលខុសត្រូវ អោយកាន់តែមានប្រសិទ្ធិភាព ?

៥- លោកនេហេមីរៀបចំគំរោងយ៉ាងហ្មត់ចត់ និងចេះប្រើឱកាសយ៉ាងត្រឹមត្រូវ ។

នៅពេលដែលឱកាសហុចឱ្យ លោកនេហេមីអាចនិយាយជាមួយព្រះចៅអធិរាជ ។ យើងអាចឃើញយ៉ាងច្បាស់ថា លោកនេហេមីបានរៀបចំខ្លួន មុននឹងទៅទូលសួរព្រះចៅអធិរាជនោះ ។

ដោយសារព្រះចៅអធិរាជចុះហត្ថលេខា លោកនេហេមីក៏បានទទួលពីព្រះចៅអធិរាជនូវ :

- ការអនុញ្ញាតិអោយធ្វើដំណើរ ។
- លិខិតផ្តាំផ្ញើ ។
- ឈើសំរាប់ធ្វើការសាងសង់ ។
- កងពលសេះអមដំណើរ ។

ព្រះចៅអធិរាជទុកចិត្តលោកនេហេមីណាស់ ហេតុនេះ ហើយបានជាព្រះអង្គជឿពាក្យគាត់ ហើយសួរថា៖ «តើលោកចង់សុំអ្វីពីយើង ?» លោកនេហេមីអរព្រះគុណព្រះជាម្ចាស់ក្នុងចិត្ត ហើយទូលប្រាប់ព្រះចៅអធិរាជពីបំណងរបស់គាត់ ។



ប្រសិនបើព្រះករុណាសព្វព្រះហឫទ័យ ហើយបើព្រះអង្គប្រណីសន្តោសដល់ទូលបង្គំមែននោះ សូមចាត់ទូលបង្គំអោយទៅស្រុកយូដា គឺទៅទីក្រុងដែលមានផ្នូរបុព្វបុរសរបស់ទូលបង្គំ ដើម្បីសង់ទីក្រុងនោះឡើងវិញផង ។

ដោយសារព្រះចៅអធិរាជជឿទុកចិត្តលោកនេហេមី ទ្រង់យល់ព្រមតាមពាក្យលោកសុំ គឺទ្រង់ប្រទានសារលិខិត ដើម្បីអោយពួកទេសាភិបាលអាណាខេត្តនានា អនុញ្ញាតិអោយលោកនេហេមីធ្វើដំណើរឆ្លងកាត់ ព្រមទាំងប្រទានសំភារៈសាងសង់ និងកងពលទាហានសេះ ដើម្បីជូនដំណើរលោកនេហេមី ។



មិនដឹងជាមានមនុស្សប៉ុន្មាននាក់ទេ ដែលសង្ឃឹមថា នឹងធ្វើអោយសំរេចបាននូវកិច្ចការធំៗ តែមិនអាចទៅដល់គោលដៅបាន ពីព្រោះតែពួកគេមិនស្មោះត្រង់ ចំពោះកិច្ចការដែលពួកគេកំពុងធ្វើនោះ ។

តើអ្នកធ្វើកិច្ចការដែលអ្នកកំពុងធ្វើ បានល្អដែរឬទេ ?

តើអ្នកបានខិតខំធ្វើកិច្ចការនោះ អោយកាន់តែប្រសើរឡើងដែរឬទេ ?

តើអ្នកធ្វើដូចម្តេចខ្លះ ដើម្បីកែឆ្នៃខ្លួនអ្នក អោយកាន់តែចេះធ្វើកិច្ចការនេះ ប្រសើរឡើង ?

បើសិនជាអ្នកមិនស្មោះត្រង់ចំពោះកិច្ចការតូចតាចទេ នោះព្រះជាម្ចាស់នឹងមិនត្រាស់ហៅអ្នកឱ្យធ្វើកិច្ចការធំៗឡើយ ។

© Project WorldReach © SEAN

៤- លោកនេហេមីស្មោះត្រង់ចំពោះកិច្ចការតូចតាច ។

ព្រះយេស៊ូមានព្រះបន្ទូលថា÷ *«អ្នកដែលស្មោះត្រង់នឹងកិច្ចការតូចតាច នឹងអាចទទួលកិច្ចការធំៗទៀត »* (លូកា ១៦:១០) ។ លោកនេហេមី ជាមនុស្សដូចនេះ ។

លោកនេហេមីជាមនុស្សដែលបំរើព្រះជាម្ចាស់ តែលោកធ្វើការងារធម្មតាដែរ ។ លោកចេះប្រើសមត្ថភាព និងចេះកែឆ្នៃចរិតលក្ខណៈរបស់លោក ទើបលោកបានឡើងកាន់មុខតំណែងជា «មហាតលិក » របស់ព្រះចៅអធិរាជ ។ មុខតំណែងនេះ ព្រះចៅអធិរាជប្រទានអោយតែអ្នក ដែលទ្រង់ទុកចិត្តបំផុតប៉ុណ្ណោះ ព្រោះនៅក្នុងសម័យកាលនោះ គេប្រើថ្នាំពុលធ្វើជាអាវុធក្នុងផ្លូវនយោបាយ (លោកនេហេមីធ្វើជា «មហាតលិក »ចាក់ភេសជ្ជៈថ្វាយព្រះចៅអធិរាជ)។

លោកនេហេមីជាអ្នកបំរើដែលល្អបំផុត ទើបនៅពេលដែលលោកទូលព្រះចៅអធិរាជពីទុក្ខកង្វល់របស់លោក ទ្រង់ប្រទានជំនួយគ្រប់យ៉ាងដល់លោកភ្លាម ។

កិច្ចការដែលលោកនេហេមីត្រូវធ្វើ

ពេលទៅដល់ទីក្រុងយេរូសាឡឹម លោកនេហេមីឃើញតែផ្ទះខ្ទមនៅក្នុងកំទេចថ្មបាក់បែក ហើយលើសពីនេះទៅទៀត បណ្តាជនសុទ្ធតែធ្លាក់ទឹកចិត្ត និងអស់សង្ឃឹម ។



លោកនេហេមីជាអ្នកដឹកនាំស្ងាហាប់ តែមានការប្រុងប្រយ័ត្ន ។ ហេតុនេះហើយបានជាលោកធ្វើដំណើរ ទៅពិនិត្យមើលទីក្រុងទាំងមូលយ៉ាងហ្មត់ចត់ នៅពេលយប់ ដើម្បីកុំឱ្យនរណាដឹងពីគំរោងការរបស់លោក ។



មានកិច្ចការធំៗជាច្រើន ដែលមិនបានសំរេចជារួបរាង ដោយសារតែគ្មានគោលដៅច្បាស់លាស់ ឬក៏គ្មានគោលដៅដែលអាចធ្វើអោយសំរេចបាន !

តើគោលដៅណាមួយខាងក្រោមនេះ ដែលច្បាស់លាស់ ហើយអាចធ្វើអោយសំរេចបាន ? គ្រូគង្វាលដែលនិយាយថា÷

☐ ខ្ញុំចង់នាំពិភពលោកទាំងមូលមកថ្វាយព្រះគ្រីស្ត ។

☐ ខ្ញុំចង់បំរើព្រះជាម្ចាស់ ។

☐ ខ្ញុំចង់បង្កើតក្រុមតាមផ្ទះចំនួនបី នៅសង្កាត់ជិតខាងបី ដែលមិនទាន់មានក្រុមជំនុំ ។

តើអ្នកមានគោលដៅដូចម្តេចខ្លះ សំរាប់កិច្ចការរបស់អ្នក ?

_____

_____

តើគោលដៅនោះច្បាស់លាស់ឬទេ ? _____

តើគោលដៅនោះ អាចធ្វើឱ្យសំរេចបានឬទេ ? _____

២- លោកនេហេមីថ្វាយស្ថានភាពនោះទៅព្រះជាម្ចាស់ ។

លោកនេហេមី មិនធ្វើសកម្មភាពតាមសន្ទុះចិត្តរបស់លោកទេ ។ លោកថ្វាយបំណងក្នុងចិត្តរបស់លោកទៅព្រះជាម្ចាស់ ។ លោកលុតជង្គង់អធិស្ឋាន ទាំងយំសោក ហើយព្រះជាម្ចាស់ធ្វើអោយចិត្តលោកពុះកញ្ជ្រោល ចង់កសាងទីក្រុងយេរូសាឡឹមឡើងវិញ ។

តើអ្នកមានថ្វាយបំណងប្រាថ្នា ឬកិច្ចការធំមួយ ឬការនិមិត្តឃើញរបស់អ្នកទៅព្រះជាម្ចាស់ ដោយរបៀបនេះដែរឬទេ ?

៣- លោកនេហេមីមានគោលដៅ ដែលច្បាស់លាស់ និងអាចធ្វើអោយសំរេចបាន សំរាប់កិច្ចការនោះ ។

គោលដៅរបស់លោកនេហេមី គឺ *«នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ ខ្ញុំមានភារៈកិច្ចធ្វើការសាងសង់កំពែងទីក្រុងយេរូសាឡឹមឡើងវិញ »* ហើយគោលដៅនេះពិបាកណាស់តែអាចធ្វើទៅបាន ។ តាំងពីពេលនោះមក គំនិតនេះក៏ក្លាយជាគោលបំណងសំខាន់បំផុត សំរាប់ជីវិតរបស់លោកនេហេមី ។

មុនដំបូងបង្អស់ លោកនេហេមីបានពិនិត្យមើលកំពែងក្រុងយេរូសាឡឹម ដើម្បីអោយដឹងពីកិរិតការងារ ដែលត្រូវធ្វើ និងរៀបចំគំរោងសកម្មភាពដើម្បីបំពេញការងារនោះ ។ បន្ទាប់មក លោកក៏គិតគូរអំពីគោលដៅដំបូង គឺលើកទឹកចិត្តបណ្តាជន ដែលធ្លាក់ទឹកចិត្តនៅក្នុងទីក្រុងយេរូសាឡឹមនោះ ។



«ពេលនោះ ខ្ញុំបានរៀបរាប់អោយពួកគេដឹងថា ព្រះជ័សប្បុរស របស់ខ្ញុំដាក់ព្រះហស្តលើខ្ញុំ ហើយព្រះចៅអធិរាជបានថ្លែងមកខ្ញុំ ដូចម្តេចខ្លះ ។ ពួកគេក៏ពោលឡើងថា÷ "ចូរយើងក្រោកឡើង ហើយនាំគ្នាសង់ !" ។ ដូច្នេះ ពួកគេក៏មានចិត្តក្លាហានបំពេញ កិច្ចការដ៏ល្អប្រសើរនេះ » ។

(នេហេមី ២:១៨)



ក្រោយពីលោកនេហេមី បានលើកទឹកចិត្តបណ្តាជនរួចហើយ លោកបែងចែកការងារសំណង់អោយពួកគេធ្វើ ។ លោកណែនាំប្រមូលពួកគេគ្រប់គ្នាអោយអាចធ្វើកិច្ចការ តាមមធ្យោបាយគ្រប់យ៉ាង ដែលអាចធ្វើទៅបាន ។

ក្រុមនិមួយៗធ្វើការងារក្នុងផ្នែកតូចមួយ ដែលសមរម្យសំរាប់ពួកគេ គឺផ្នែកដែលស្ថិតនៅមុខទីកន្លែងដែលគេរស់នៅ ។ ទាំងសង្ឃ ទាំងពួកលេវី ទាំងពួកអ្នកជំនួញនាំគ្នាមកសាងសង់ទាំងអស់គ្នា ។

១- លោកនេហេមីយល់ច្បាស់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ជនជាតិយូដាឯទៀតជាច្រើន ក៏ដឹងពីសភាពបាក់បែកខ្ទេចខ្ទីរបស់ទីក្រុងយេរូសាឡឹមដែរ ។ ប៉ុន្តែ មានតែលោកនេហេមីម្នាក់គត់ ដែលគិតពីការនេះជាប់ក្នុងចិត្ត នឹកខ្មាស់អៀនចំពោះស្ថានភាពបែបនេះ ហើយក៏រៀបចំធ្វើកិច្ចការដើម្បីកែប្រែស្ថានភាពនោះ ។

តើអ្នកមានបំណងចង់ធ្វើកិច្ចការថ្វាយព្រះជាម្ចាស់ខ្លាំងក្លាដូចនេះ ដែរឬទេ ?

☐ ខ្ញុំមានបំណងចង់ធ្វើ ។

☐ ខ្ញុំអត់មានបំណងចង់ធ្វើទេ ។

តើសេចក្តីប៉ងប្រាថ្នាណាមួយ ដែលកំពុងឆេះឆួលនៅក្នុងចិត្តរបស់អ្នក ?

ឧបសគ្គ

ការសាងសង់នោះ មិនស្រួលប៉ុន្មានទេ ដោយសារមានពួកស្តេច ដែលនៅជិតខាងធ្វើការជំទាស់ ព្រោះមិនចង់ឃើញទីក្រុងយេរូ-សាឡឹមត្រូវគេសាងសង់ឡើងវិញ ។ ពួកស្តេចទាំងនោះ គំរាមថា គេនឹងវាយលុកកំទេចសំណង់ ដែលបណ្តាជនកំពុងធ្វើនោះ ។



តើអ្នកចង់ធ្វើតាមគំរូរបស់លោកនេហេមីដែរឬទេ ?



ប៉ុន្តែ លោកនេហេមីមិនរាថយទេ :

«ចាប់ពីថ្ងៃនោះមក គ្នាខ្ញុំចំនួនពាក់កណ្តាល ធ្វើកិច្ចការសំណង់ ហើយចំនួនពាក់កណ្តាលទៀត កាន់លំពែង កាន់ខែល កាន់ធ្នូ និងប្រដាប់ការពារខ្លួន... ។ អស់អ្នកដែលសង់កំពែង អស់អ្នកដែលលីសែង ឬ ជីកជញ្ជាំន ធ្វើការដៃម្ខាង កាន់អាវុធដៃម្ខាង ។ រីឯអ្នកបូកឥដ្ឋវិញ គេស្តាយដាវនៅនឹងចង្កេះ ហើយបំពេញការងាររបស់ខ្លួន ។ រីឯអ្នកផ្លុំស្នែងឈរនៅក្បែរខ្ញុំ » ។

(នេហេមី ៤:១៦-១៨ ឬ ១០-១២)



លោកអែសរ៉ាបើកគម្ពីរ ហើយប្រជាជនបានឃើញទាំងអស់គ្នា ដ្បិតលោកឈរនៅត្រង់កន្លែងខ្ពស់ជាងគេ ។ ពេលគម្ពីរបើកចំហ ប្រជាជនទាំងមូល ក៏ក្រោកឈរឡើង ។ លោកអែសរ៉ាលើកតម្កើងព្រះអម្ចាស់ ជាព្រះដ៏ឧត្តុង្គឧត្តម ហើយប្រជាជនទាំងមូលឆ្លើយតបវិញ ទាំងលើកដៃឡើងលើថា "អាម៉ែន ! អាម៉ែន !" រួចក្រាបថ្វាយបង្គំព្រះអម្ចាស់អោនមុខដល់ដី... ។ បន្ទាប់មក ពួកគេក្រោកឈរឡើងតាមកន្លែងរៀងៗខ្លួន ហើយស្តាប់គម្ពីរវិន័យរបស់ព្រះអម្ចាស់ជាព្រះនៃពួកគេ ក្នុងអំឡុងពេលបីម៉ោង រួចបីម៉ោងទៀត ពួកគេសារភាពអំពើបាប និងក្រាបថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់ពួកគេ » ។

(នេហេមី ៨:១, ៨:៥-៦, ៩:៣)

ការភ្ញាក់រលឹកនេះ បណ្តាលអោយមានការកែប្រែយ៉ាងខ្លាំង ក្នុងចំណោមបណ្តាជន ហើយនាំអោយប្រជារាស្ត្ររបស់ព្រះជាម្ចាស់បានទទួលព្រះពរ ។ ការទាំងអស់នេះ កើតមានដោយសារតែមនុស្សម្នាក់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ត្រាស់ហៅគាត់ ហើយគាត់ថ្វាយខ្លួនទាំងស្រុង ដើម្បីបំរើព្រះអង្គអស់ពីកម្លាំងកាយ និងអស់ពីកម្លាំងចិត្តរបស់ខ្លួន ។

ព្រះជាម្ចាស់ប្រទានព្រះពរ

កិច្ចការដែលលោកនេហេមីបានធ្វើ បណ្តាលអោយបណ្តាជនភ្ញាក់រលឹកស្វែងរកព្រះជាម្ចាស់ជាខ្លាំង :

«លុះដល់ខែទីប្រាំពីរ ជនជាតិអ៊ីស្រាអែល ដែលរស់នៅតាមក្រុងរបស់ខ្លួនបានមកជួបជុំគ្នាដោយមានចិត្តគំនិតតែមួយ ក្នុងព្រលានដែលស្ថិតនៅខាងមុខទ្វារគង្គា ។ ពួកគេសុំអោយលោកឪជាចារ្យអែសរ៉ាជាបណ្ឌិតខាងវិន័យ យកគម្ពីរវិន័យរបស់លោកម៉ូសេ គឺវិន័យដែលព្រះអម្ចាស់ប្រទានមកអោយជនជាតិអ៊ីស្រាអែលកាន់តាម...។



មិនមែនគ្រាន់តែមានការជំទាស់តែពីខាងក្រៅប៉ុណ្ណោះទេ នៅក្នុងចំណោមពួកគេផ្ទាល់ ក៏មានបញ្ហាដែរ ។ ជនជាតិយូដាដែលជាអ្នកមានខ្លះកេងប្រវ័ញ្ចលើជនជាតិយូដាឯទៀត ដោយទារបំណុលឬយកការយ៉ាងធ្ងន់ធ្ងរ ឬរឹបអូសយករបស់ទ្រព្យ ដែលកូនបំណុលយកមកបញ្ចាំ ដើម្បីខ្ចីប្រាក់ ឬខ្ចីចំណីអាហារ ។ លោកនេហេមីស្តីបន្ទោសដល់ពួកអ្នកកេងប្រវ័ញ្ចទាំងនោះ ពួកគេក៏ឆ្លើយមកលោកវិញថា÷ *«យើងខ្ញុំសុខចិត្តប្រគល់អោយពួកគេវិញ ហើយយើងខ្ញុំក៏មិនទាមទារអ្វីពីពួកគេទៀតដែរ យើងខ្ញុំធ្វើតាមពាក្យរបស់លោក »* (នេហេមី ៥:១២) ។



លទ្ធផល

ប៉ុន្តែ ទោះជាមានឧបសគ្គយ៉ាងណាក៏ដោយ ក៏កិច្ចការដែលគេទុកចោលមិនធ្វើអស់រយៈពេល១០០ឆ្នាំនោះ ត្រូវបានធ្វើហើយក្នុងរយៈពេល៥២ថៃ ហើយបណ្តាជនដែលពោរពេញដោយអំណរ និងការសើចសរសើរ បានមកជួបជុំគ្នា ដើម្បីអរព្រះគុណព្រះជាម្ចាស់ និង កោតសរសើរពីកិច្ចការដែលពួកគេបានធ្វើ ។



មនុស្សតែម្នាក់ ដែលមានចិត្តចង់ដោះស្រាយបញ្ហាប្រឈមមុខមួយ ដោយពឹងលើព្រះជាម្ចាស់ទាំងស្រុងអាចធ្វើអោយសំរេចកិច្ចការ ដែលមនុស្សភាគច្រើនមិនអាចមានសមត្ថភាពធ្វើបាន ។



© Project WorldReach © SEAN